និងប្រជាជនវៀតណាមបានឡើយ» ។ ហើយបន្ទាប់ពីការចាប់ផ្តើមនៃការវាយសំរុកផ្តាច់ព្រ័ត្រលើក្រុងភ្នំពេញ នៅថ្ងៃទី១មករា១៩៧៥, ឡេ-ឌឹកថូ បានទទួលលិខិតមួយច្បាប់ទៀតពីសាឡុត-សរដែលមានន័យថា ៖ «ជំនួយវៀតណាមបានរួមចំណែកយ៉ាងធំធេង ក្នុងជ័យជំនះរបស់បក្សកុម្មុយនិស្តកម្ពុជា» ។

ការវាយសម្រុកនេះមានអមបន្ត ដោយការសម្លាប់រង្គាល ទៅលើរាស្រ្តសាមញ្ញតាមតំបន់ដែលស្ថិតនៅត្រើយខាងកើតនៃទន្លេមេគង្គ, ក៏ដូចជានៅភាគខាងជើង និងភាគខាងត្បូងនៃរដ្ឋធានីដែរ ។ ចាប់ពីថ្ងៃទី១៦កុម្ភៈ១៩៧៥, អាមេរិកាំងចាប់ផ្តើមធ្វើ«ស្ពានអាកាស» ដែលសំដៅផ្តល់ស្បៀងទៅក្រុងភ្នំពេញនិងកងកម្លាំងប្រយុទ្ធបន្ទាប់ពីផ្លូវគមនាគមន៍ជើងទឹកនិងជើងគោក ត្រូវបានកាត់ផ្តាច់អស់ ។

នៅថ្ងៃទី១២មិនា១៩៧៥, ឧត្តមសេនិយសុស្តែន-ហ្វែរណង់ដេស៍, ជាអគ្គបញ្ជាការនៃកងយោធពលខេមរជាតិ, បានសុំលាពីតំណែង ដើម្បីជៀសវាងការជំទាស់ជាយថាហេតុ ក្នុងកិច្ចចរចាជាមួយខ្មែរក្រហម ។ រូបគាត់ត្រូវបានជំនួសដោយឧត្តមសេនិយសក់-ស៊ុតសាខន ដែលបានក្លាយជានាយអគ្គសេនាធិការថ្មី ។ ពីព្រោះចាប់តាំងពីខែមិនា១៩៧៤, ឯកអគ្គរដ្ឋទូតថ្មីនៃសហរដ្ឋអាមេរិក ជ្ហន-ហ្កាន់ធើឌៀន, បានមកកាន់តំណែងនៅស្ថានទូតឯក្រុងភ្នំពេញ ។ ហ្កាន់ធើឌៀន បានសាកល្បងរកដំណោះស្រាយស្តីពីវិបត្តិកម្ពុជាតាមកិច្ចចរចា, ដូចបានធ្វើរួចហើយ រវាងពួកប៉ាថេត-ឡាវនិងរដ្ឋាភិបាលលាវ។ រហូតដល់ចុងឆ្នាំ១៩៧៤, ហ្កាន់ធើឌៀនបានទាក់ទងជាមួយឯកអគ្គរដ្ឋទូតបារាំង, ម៉ាណាក់, ប្រចាំការនៅប៉េកាំង ជាទីដែលស្តេចសីហនុស្ថិតនៅទីនោះ ។ ម៉ាណាក់ និងអនុប្រធាន ម៉ាឡូ បានជួយជ្រោមជ្រែងហ្កាធើឌៀនឲ្យមានកិច្ចប្រជុំមួយនៅម៉ាទីនីក រវាងប្រធានាធិបតីបារាំង វ៉ាឡ្សឺរី ហ្សីស្កាដ៍ ដេស្តាំងជាមួយប្រធានាធិបតីអាមេរិកាំង ហ្សេរ៉ាល់-ហ្វដ៍, ដែលទាំងពីរនាក់បានអញ្ជើញស្តេចសីហនុ ឲ្យត្រឡប់មកកាន់អំណាចវិញ ។ ប៉ុន្តែសីហនុបានឆ្លើយថា ៖ «ហួសពេលហើយ» (ប្រសាសន៍ផ្ទាល់របស់ជ្ហន-ហ្កាន់ធើឌៀន, អតីតឯងអគ្គរដ្ឋទូតអាមេរិកាំងប្រចាំក្រុងភ្នំពេញ, ក្នុងភាពយន្តឯកសារ «ការរលំនៃក្រុងភ្នំពេញ») ។ ពិតហើយ, ព្រោះអនាគតនៃប្រជារាស្រ្តខ្មែរនិងប្រទេសខ្មែរ បានធ្លាក់ក្នុងកណ្តាប់ដៃចិននិងយួនតាំងពីយូរលង់ ហើយគោលបំណងនៃ«មហាមិត្តតាំងពីរ»របស់ស្តេចសីហនុ គឺកែប្រែកម្ពុជាឲ្យទៅជារដ្ឋកុម្មុយនិស្ត, ដូច្នេះការអនុញ្ញាតសីហនុ ឲ្យមកសោយរាជ្យវិញ ជារឿងយលសប្តិ ។

ដោយសង្ឃឹមថា ការចេញដំណើររបស់លោក នឹងបើកចំហឲ្យមានការចរចាជាមួយខ្មែរក្រហម, សេនាប្រមុខលន់-លន់បានចាកចោលទីក្រុងភ្នំពេញ ទៅកាន់ហូណូលូលូ, កោះហាវ៉ៃ, តាមសំណូមពរពីរដ្ឋាភិបាល ។ ចំណែកឧត្តមសេនិយសូ

កាំខូយ, ជាប្រធានព្រឹទ្ធសភា, ត្រូវបានតែងតាំងជាប្រមុខរដ្ឋស្តីទី ។ ក្នុងខណៈនោះ,
ខ្មែរក្រហមដណ្តើមយកបានទីក្រុងអ្នកលឿង ជាទីតាំងសំខាន់ចុងក្រោយ ដែលកា
ន់កាប់ដោយកងទ័ពសាធារណរដ្ឋតាមដងទន្លេមេគង្គ, នៅចម្ងាយ៦០គ.ម. ខាងអា
គ្នេយ៍ទីក្រុងភ្នំពេញ តាមផ្លូវជាតិលេខ១ ។ នៅថ្ងៃទី១២មេសា១៩៧៥, កងឧទ្ធម្ភាគ
ចក្រ ដែលចេញពីនាវាផ្ទុកយន្តហោះនៅឈូងសមុទ្រសៀម បានមកជម្លៀសសមា
ជិកនិងបុគ្គលិកនៃស្ថានទូតអាមេរិកាំង ។ ឧត្តមសេនិយសូកាំខូយ ក៏បានចេញដំ-
ណើរក្នុងពេលនោះដែរ ។ នៅថ្ងៃទី១៥មេសា១៩៧៥, ខ្មែរក្រហមចូលកាន់កាប់ទីក្រុ
ងតាខ្មៅ នៅចម្ងាយ១០គ.ម. ខាងត្បូងក្រុងភ្នំពេញ ហើយវាយសំរុកឆ្ពោះទៅស្ពាន
មុនីវង្ស ព្រមទាំងអាកាសយានដ្ឋានផង ។

ស្តីពី«ជ័យជំនះ»របស់ខ្មែរក្រហម នៅថ្ងៃទី១៧មេសា១៩៧៥, តាមការអះអាង
របស់ វីល្លីយ៉ាម-ឌីយើ នៅក្នុងសៀវភៅ «ចិននិងវៀតណាម ៖ ឫសគល់នៃវិវាទ»,
បេឃើលី, កាលីហ្វ័រនៀ, ទំព័រ៦០, និងការអះអាងរបស់ អ៊ីសាក់ស៍ នៅក្នុងសៀវ-
ភៅឈ្មោះឈ្មោះ «ខ្វះកិត្តិយស», ទំព័រ២៧៦ «ពលទាហានយៀកកុង២កងពលធំ
បានចូលរួមក្នុងការវាយសំរុកផ្តាច់ព្រ័ត្រលើក្រុងភ្នំពេញ» ។ ចំណែក ខេ ហ្គាហ្វ៍, អ្ន
កនិពន្ធសៀវភៅឈ្មោះ «ឫសកែវនៃរបបប៉ុល-ពតនៅកម្ពុជា», ១៩៨៧, ទំព័រ១៣៩,
បានបញ្ជាក់ដោយផ្អែកទៅលើបទសម្ភាសន៍មួយនៅប្រទេសយួនថា ៖ «កាំភ្លើងធំ
របស់យួនបានចូលរួម ក្នុងការវាយលុក ដើម្បីបំបែកក្រុងភ្នំពេញ» ។ អ្នកនិពន្ធចុង
ក្រោយ, ប៊ីរឆេត៍, ដែលបានសរសេរសៀវភៅ «ត្រីកោណចិន-កម្ពុជា-វៀតណាម»
ទំព័រ១៩៩ បញ្ជាក់ថា ៖ «នៅចុងឆ្នាំ១៩៧៤, សាឡុត-សរបានធ្វើដំណើរទៅប៉េកាំង
និងហាណូយ ដើម្បីស្នើរកជំនួយយោធា ។ យួនខាងជើងបានផ្តល់កាំភ្លើងធំធុន
ធ្ងន់ និងអ្នកបាញ់មួយចំនួន ។ ទស្សនកិច្ចនេះពុំត្រូវបានផ្សព្វផ្សាយឲ្យដឹងទេ, សា
ឡុតសរ-ប៉ុលពតតែងបដិសេធជានិច្ច នូវការចូលរួមណាមួយពីយួន នៅក្នុងជ័យ
ជំនះជាប្រវត្តិសាស្ត្រ នៅថ្ងៃទី១៧មេសា១៩៧៥នេះ» ។

ប៉ុន្តែកត្តាធំៗដែលបានជំរុញសាឡុត-សរឲ្យសំរេចបាន «ជ័យជំនះជាប្រវត្តិ-
សាស្ត្រ»នេះ មាន៦ចំណុចគឺ ៖

១- ដោយសារសភានិងប្រជារាស្ត្រអាមេរិកាំងឈប់គាំទ្រសង្គ្រាម ឈប់ផ្តល់
ជំនួយចំពោះសាធារណរដ្ឋខ្មែរ ។

២- ដោយសារសហភាពសូវៀត ប្រាថ្នាឲ្យកម្ពុជាក្លាយជារដ្ឋកុម្មុយនិស្ត នៅក្នុង
សហព័ន្ធឥណ្ឌូចិន តាមគំរោងរបស់អង្គការកុម្មុយនិស្តអន្តរជាតិសូវៀត ។

៣- ដោយសារចិនកុម្មុយនិស្ត ចង់ឲ្យកម្ពុជារបស់ប៉ុល-ពត ក្លាយជាកូនសម្ព័-
យរបស់គេ សំរាប់ទុកនៅក្រោយខ្នងយួន ដើម្បីទប់ទល់ជាមួយឥទ្ធិពលសូវៀត និ

ងសំរាប់ពង្រីកឥទ្ធិពលចិននៅក្នុងប្រទេសសៀម...។

៤- ដោយសារយួនកុម្មុយនិស្ត មានបំណងឲ្យផែនការយៀកមិញ ដែលពួកគេបានបង្កបង្កើតតាំងពីឆ្នាំ១៩៣០នៅកម្ពុជា បានទៅដល់ទីដៅ ដើម្បីឲ្យខ្មែរបានកាប់សម្លាប់គ្នាឯងជំនួសពួកគេ ទៅតាមលទ្ធិកុម្មុយនិស្តព្រៃផ្សៃ រួចហើយខ្មែរត្រូវនៅក្រោមរណបយួន ។

៥- ដោយសារនយោបាយដ៏វាងវៃនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជារបស់សីហនុ ដែលមានអនុភាពខ្លាំងក្លាលើឆាកអន្តរជាតិ ។

៦- ដោយសារបញ្ញវ័ន្តខ្មែរមួយចំនួន ដែលជួបប្រទះអំពើពុករលួយ អំពើផ្តាច់ការ និងអំពើអយុត្តិធម៌ក្នុងសង្គមខ្មែរ ហើយនឹកមមៃដល់ភាពស្អាតស្អំ ស្មើភាពគ្នានៅក្នុងទ្រឹស្តីនៃលទ្ធិម៉ាក់ស៊ីស-ឡេនីនីស្ត ។

ភ្លើងទាំងប្រាំមួយ ដែលសុទ្ធតែជាមធ្យោបាយសំរាប់សំរួលដល់អំពើឃ្លានពានរបស់សត្រូវយួន បានបាក់សង្កត់ព្រមគ្នាមកលើប្រជារាស្ត្រខ្មែរ នៅពេលដែលរាស្ត្រខ្មែរ ត្រូវបានបណ្តេញចេញពីផ្ទះសំបែង ពីទីក្រុង ដោយចោលទ្រព្យសម្បត្តិដោយបែកបាក់គ្រួសារ តាមរបៀបព្រៃផ្សៃរកទីបំផុតគ្មាន ។ អ្វីដែលខ្ញុំបាទបានឃើញច្បាស់ប្រាកដ គឺវិធានការណ៍៤ ក្នុងចំណោមវិធានការណ៍៥ ដែលសត្រូវយួនធ្លាប់បានប្រើ សំរាប់បំបាត់ពូជខ្មែរ នៅមុនសម័យអាណានិគមបារាំង, បានចាប់ផ្តើមដំណើរការជាស្វ័យប្រវត្តិដូចជា ៖

★ <u>វិធានការណ៍ទី១</u> ៖ «បំផ្លាញពុទ្ធសាសនា» ឬព្រលឹងខ្មែរ

- មានការចាប់ផ្សឹកព្រះសង្ឃ ទូទាំងប្រទេស ។
- ប្រមូលពុទ្ធបដិមាករបោះចោលក្នុងស្រះ ឬវាយកំទេចចោល តាមទ្រឹស្តីថា «ព្រះមួយអង្គ ស៊ីម៉ង់មួយបាវ» ។
- ដុតបំផ្លាញគម្ពីរ សាស្ត្រា និងសៀវភៅធម៌ ។
- រុះរើបំផ្លាញកុដិ វិហារ យកទៅធ្វើសំណង់ផ្សេងៗ ឬយកដែកសរសៃ ។

★ <u>វិធានការណ៍ទី២</u> ៖ «បំផ្លាញសម្បត្តិធម្មជាតិខ្មែរ» ឬសំណង់ក្នុងប្រទេស ឬសាច់ ឈាម សរសៃខ្មែរ ។

- កាប់បំផ្លាញព្រៃឈើ ធ្វើដីដំណាំថ្មី ដោយទុកដីស្រែចំការចាស់ចោលទំនេរ។
- ផលដំណាំត្រូវលិចលង់ដោយទឹកជំនន់ ដែលបណ្តាលពីទំនប់ ។
- សត្វពាហណៈគោក្របីត្រូវស្លាប់ ក្នុងក្បួនរទេះដឹកជញ្ជូន ឬដោយការភ្ជួររាស់ទាំងព្រឹកទាំងល្ងាច ។
- ផ្ទះសំបែង, សាលារៀន, អាគារនានា ត្រូវរុះរើយកទៅសង់មន្ទីរសំរាប់កម្មាភិបាលនៅក្នុងព្រៃ ។

- ផ្លូវថ្នល់ ស្ពានតូចធំ ត្រូវបានបំផ្លាញខ្ទេចអស់ តាំងពីពេលសង្គ្រាម ។

★ វិធានការណ៍ទី៣ ៖ «បំបាត់មេដឹកនាំខ្មែរ» ឬមាត់ ច្រមុះ ត្រចៀក ភ្នែក ខួរក្បាលខ្មែរ

- មន្ត្រី អ្នករដ្ឋការតូចធំ ខ្ញុំរដ្ឋការ ត្រូវបានប្រមូលទៅសម្លាប់ចោលទាំងក្រុម ។
- នាយទាហាន នាយទាហានរង គ្រប់បណ្តាសក្តិ ត្រូវបានប្រមូលទៅទទួល«សម្តេចឪ» ហើយត្រូវស្លាប់គរជើងគ្នា ។
- បញ្ញវ័ន្ត និស្សិត សិស្សថ្នាក់ទីបញ្ចប់ សុទ្ធតែត្រូវបានចាត់ទុកជាខ្សែសង្វាក់សេ.អ៊ី.អាអាមេរិកាំង ត្រូវស្លាប់ទាំងរណ្តៅ ។ ចំណែកសិស្សថ្នាក់បន្ទាប់ បានទទួលពាក្យណែនាំថា «បើចង់បានបាក់អង្គ ឬបាក់ឌុប ត្រូវលើកទំនប់ ឬជីកប្រឡាយ» ។

★ វិធានការណ៍ទី៤ ៖ «បំបាត់ប្រជារាស្ត្រខ្មែរ» ឬដៃជើង អង្គប្រាណខ្មែរ

• ប្រជាជនថ្មីទាំងអស់ជាឈ្លើយសឹក ជាអ្នកចាញ់សង្គ្រាម និងជាខ្មាំង ព្រោះមិនបានចូលរួមជាមួយបដិវត្តន៍ឲ្យទាន់ពេល ។ កំហុសសូម្បីត្រឹមពាក្យមួយម៉ាត់ អាចត្រូវកាត់ទោសដោយចៅក្រមក្មេងៗ, អាចត្រូវប្រហារជីវិតដោយពេជ្ឈឃាតក្មេងៗ។ ទាំងអស់គ្នាត្រូវធ្វើ«ពលកម្ម» ដោយគ្មានពេលម៉ោងកំណត់ គ្មានសំលៀកបំពាក់, គ្មានចំណីអាហារ និងថ្នាំសង្កូវគ្រប់គ្រាន់ ។ ការបាត់បង់សេរីភាពទាំង១០០ភាគរយរបស់ប្រជារាស្ត្រខ្មែរ នៅជំនាន់នោះស្ថិតនៅត្រង់ ៖ «ឃ្លានមិនហ៊ានមាត់, ឈឺមិនហ៊ានថ្ងូរ និងស្លាប់មិនហ៊ានយំ» ។

ប្រជាជនចាស់មួយចំនួន ដែលដើរមិនទាន់«កងប្រវត្តិសាស្ត្រ» ក៏ត្រូវបានចាត់ទុកជា «ខ្មាំង» ដូចគ្នា ។

ចំណែក វិធានការណ៍ទី៥ គឺ «បញ្ចូលជនជាតិយួន» លោកអ្នកអាននឹងបានឃើញក្នុងដំណាក់មួយទៀត ក្រោយថ្ងៃទី៧មករា១៩៧៩ ។

នៅទីបំផុត, កម្មាភិបាលនិងយោធាដែលបានបំរើបដិវត្តន៍ ក៏ជាខ្មាំងដែរ, ព្រោះតែពាក្យចោទប្រកាន់ថា «ក្បាលយួនខ្លួនខ្មែរ» ឬ«អាយ៉ងយួន» ។ ប៉ុន្តែតាមពិត ក្នុងជួរខ្មែរក្រហមនិងជួរណាសិរ្ស, ទាំងដើមចោទទាំងចុងចោទ, ពីថ្នាក់ទាបបំផុតដល់ថ្នាក់កំពូល សុទ្ធជា«អាយ៉ងយួន»ទាំងអស់, ព្រោះយួនជាអ្នកបណ្តុះបណ្តាល ជាអ្នកឲ្យដំបូន្មាន ក្នុងបំណងសំរាប់បំរើផលប្រយោជន៍របស់យួន ហើយមិនដែលឃើញខ្មែរទាំងអស់នេះ បានធ្វើចៅហ្វាយលើយួនទេ ។ ខ្មែរក្លាយជាសត្រូវវាងខ្មែរគ្នាឯងពេញប្រទេស រហូតដល់សព្វថ្ងៃ ដោយសារនយោបាយរបស់ទមិឡ អន្យតិរ្ថិយកុម្មុយនិស្ត ដែលហូ-ជីមិញបានយកមកបង្រៀនដល់ខ្មែរ ដូចពាក្យស្លោកក្នុងពុទ្ធទំនាយថា ៖ «ភ្នែកពាំផ្លែល្វា វាយគ្រប់ស្រុក តំណទៅមុខ អ្នកស្រុកស្រែកយំ»

ពិតហើយ, សត្វក្អែកគឺអ្នកដើឃោសនា បញ្ចុះបញ្ចូល និយាយកោកកាក ដែលនិយមតែសំលៀកបំពាក់ផាឱបខ្មៅ ។ បន្ទាប់មកផ្លែល្វា គឺទ្រឹស្តីកុម្មុយនិស្ត ដែលអួតអាងអំពីភាពស្អាតស្អំ សំបូរបែប ស្មើភាព មហាអស្ចារ្យជាដើម, ប៉ុន្តែដូចពាក្យឧបទេសខ្មែរមួយឃ្លាទៀតថា ៖ «លោកថាល្វាផង សំបកក្រៅហោង ភ្លឺផ្លេកយល់យង់ រីឯក្នុងផ្លែ សឹងតែមមង់ ក្រាស់ក្រៃនៅក្នុង ន័យនោះសោតណា» ។ ចំណែកអ្នកស្រុកស្រែកយំនោះ ដោយហេតុអ្វី ? គឺដោយសារបុណ្យខ្មោចមួយ ដែលមានសាកសពជិតបីលាននាក់ ។

គ្មាននរណាម្នាក់ទទួលខ្លួនខុស ចំពោះមហាវិនាសកម្មនេះ ព្យយ៉ាងហោចណាស់ ភ្ញាក់រលឹកអំពីកំហុស ហើយឆាប់ស្មុះស្មាររកនយោបាយ ដើម្បីបញ្ចប់អំពើឈ្លានពានរបស់យួនឡើយ ។ ដូចជាក្នុងបទសម្ភាសន៍មួយ ដែលហ្វ្រង់-ឡាគូទៀរ៍ បានចោទសំនួរទៅនរោត្តម-សីហនុថា ៖ «នៅឆ្នាំ១៩៧០, ហេតុអ្វីបានជាសម្តេចជួយជ្រោមជ្រែងក្រុមប៉ុល-ពត ឲ្យទទួលបានជ័យជំនះ ដែលបានបណ្តាលឲ្យរាស្ត្រខ្មែរស្លាប់ជាងពីរលាននាក់ ?» ។ ចម្លើយ «ព្រោះខ្ញុំករុណាមិនដឹងថា ក្រុមប៉ុល-ពតសាហាវព្រៃផ្សៃដូច្នេះ» ។

ក្រោយ«ជ័យជំនះជាប្រវត្តិសាស្ត្រ»នៅថ្ងៃទី១៧មេសា១៩៧៥, ដោយបារម្ភឥតឈប់ឈរនឹងពួក«អាយ៉ងយួន», ប៉ុល-ពតសម្ងំលាក់មុខ ជាមួយការសង្កិតសំរាំង «ខ្មាំង»នៅទួលស្លែង ឬត្រពាំងក្រឡឹងទី២, ដោយហេតុថា នៅក្នុងបក្សកុម្មុយនិស្តកម្ពុជា, នៅមុនឆ្នាំ១៩៦៦ មានឈ្មោះថា បក្សពលករកម្ពុជា, ហើយមុនសមាជបក្សលើកទី២ នៅឆ្នាំ១៩៦០ មានឈ្មោះថា បក្សប្រជាជនបដិវត្តន៍កម្ពុជា មានខ្មែរក្រហមពីរប្រភេទ ដែលតាំងខ្លួនជាអ្នកជាតិនិយមដូចគ្នា, ប៉ុន្តែមួយក្រុមជានិស្សិតកុម្មុយនិស្តមកពីប្រទេសបារាំងឬសៀមជំនាន់ឆ្នាំ៥០, មួយក្រុមទៀត ជាខ្មែរយៀកមិញជំនាន់ឆ្នាំ៤០ ។ ក្រោយជ័យជំនះ, ខ្មែរក្រហមជានិស្សិត ភាគច្រើនបានកាន់កាប់មុខតំណែងក្នុងមជ្ឈិមបក្សនៅភ្នំពេញ ដូចជាខៀវ-សំផន, សុន-សេន, អៀង-សារី, នួន-ជា, ប៉ុល-ពតជាដើម, ហើយខ្មែរក្រហមជំនាន់យៀកមិញ ភាគច្រើនចូលកាន់កាប់មុខនាទី ជាកម្មាភិបាលបក្ស នៅតាមភូមិភាគឬតំបន់ ដូចជា ជូ-ចិត្ត លេខាធិការនៅភូមិភាគបស្ចឹម, មូល-សម្បត្តិ (រស់-ញឹម) លេខាធិការនៅភូមិភាគពាយ័ព្យ, សោ-ភឹម លេខាធិការនៅភូមិភាគបូព៌ា, ណី-សារ៉ាន (យ៉ា) លេខាធិការនៅភូមិភាគឦសាន, ព្រុំ-សម្បត្តិគណបញ្ជាការកងពលធំ១៧០, កែវ-មុនី, កែវ-មាសជាដើម។

វិបត្តិផ្ទៃក្នុងរបស់ខ្មែរក្រហម បានចាប់ផ្តើមនៅពេល ដែលទស្សនាវដ្តីយុវកក (យុវជនកុម្មុយនិស្តកម្ពុជា) របស់បក្ស បានចុះផ្សាយអត្ថបទ១០ទំព័រ ដើម្បីរំលឹកដល់ឆ្នាំខួបទី២៥របស់បក្ស ដោយបើកកកាយឡើងវិញ អំពីការបង្កបង្កើតបក្សប្រ-